## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : ក្រញូង

ឈ្មោះវិទ្យាសាស្ត្រ : *Dalbergia cochinchinensis* **Pierre**

អំបូរ : **Leguminosae**

ចំណាត់ថ្នាក់ជាតិ : **ឈើប្រណីត**

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

ដើមក្រញូងមានដើមកំណើតនៅបណ្តាប្រទេសឥណ្ឌូចិនដូចជា កម្ពុជា វៀតណាម ឡាវ ថៃ និងប្រទេសដែលនៅជិតខាង។ វាច្រើនដុះនៅក្នុងតំបន់ព្រៃដីទំនាបដែលមានរបបទឹកភ្លៀងប្រចាំឆ្នាំពី ១២០០-១៦៥០ម.ម ហើយមានសីតុណ្ហភាពប្រចាំឆ្នាំពី ២០-៣២អង្សាសេ និង មានសីតុណ្ហភាពទាបបំផុតត្រឹម១០អង្សាសេ។ ដើមក្រញូងត្រូវការសំណើមមធ្យម ចូលចិត្តពន្លឺថ្ងៃ ហើយធន់នឹងរដូវរាំងស្ងួតរយ:ពេលយូរ។ ប្រភេទនេះមិនទាមទារលក្ខខណ្ឌដីល្អប៉ុន្មានទេ ប៉ុន្តែវាចូលចិត្តដុះនៅលើដីឥដ្ឋ ល្បាយខ្សាច់ និង ដីដែលមានជាតិកំបោរ។ ក្រញូងដុះលូតលាស់នៅក្នុងព្រៃល្បោះ និង ព្រៃពាក់កណ្តាលស្រោង ហើយជារឿយៗគេជួបប្រទះប្រភេទនេះដុះជាជ្រុំៗ ប្រមូលផ្តុំច្រើននៅរយ:កំពស់ពី៤០០-៥០០ម ធៀបទៅនឹងនីវ៉ូសមុទ្រ។ តាមផែនទីរបាយដំណុះឈើអាទិភាពដែលរៀបចំដោយគំរោងគ្រាប់ពូជឈើកម្ពុជា គេសង្កេតឃើញថានៅប្រទេសកម្ពុជាក្រញូងមានដុះនៅក្នុងខេត្តមួយចំនួន ដូចជា: រតនគីរី ក្រចេះ មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ សៀមរាប កំពង់ធំ ពោធិ៍សាត់ និងកោះកុង។ នៅក្នុងខេត្តសៀមរាប គំរោងគ្រាប់ពូជឈើកម្ពុជាបានបង្កើតប្រភពគ្រាប់ពូជឈើក្រញូងក្នុងព្រៃធម្មជាតិមួយកន្លែង មានទីតាំងឋិតនៅក្នុងឃុំស្រែណូយ ស្រុកវ៉ារិន ដែលមានផ្ទៃដីទំហំ ៥០ហ.ត និង មានដើមមេដែលបានជ្រើសរើសសំរាប់បេះប្រមូលគ្រាប់ពូជចំនួន ១២១ដើម។

## ៣- ការប្រើប្រាស់

ក្រញូងជាប្រភេទឈើមានទំហំធំ ដែលអាចទាក់ទាញក្នុងការដាំដុះ។ សាច់ឈើមានសរសៃល្អណាស់ មានស្រាយពណ៌ប្រផេះព្រឿងៗ ខ្លឹមរឹង មានពណ៌ក្រហមត្នោតស្ទើរតែពណ៌ខ្មៅ សាច់ឈើហាប់ម៉ដ្ឋល្អ ជាប់រឹងធ្ងន់។ ប្រភេទនេះមានដង់ស៊ីតេស្មើនឹង ១,០៩ ងាយស្រួលកែច្នៃ ជាប់មាំ មិនប្រេះបែក នៅពេលស្ងួត ប្រើបានយូរ លើសពីនេះធន់នឹងពពួកសត្វល្អិត និង កណ្តៀរ។ ដើមឈើមានទំរង់មិនសូវត្រង់ទេ និងមាននិន្នាការផលិតនូវពកឈើ។ ដោយឋិតនៅក្នុងអំបូរសិម្ពិកូល ដើមក្រញូងមានលទ្ធភាពផ្តល់ជាតិអាសូតដល់ដី ដូច្នេះគេអាចដាំតាមរបៀបកសិ-រុក្ខកម្ម និងដាំសំរាប់កែប្រែដីឱ្យល្អប្រសើរឡើង។ គេនិយមប្រើឈើក្រញូងជាគ្រឿងសំណង់ គ្រឿងចម្លាក់ គ្រឿងសង្ហារឹមដែលមានគុណភាពប្រណីត តុ ទូ ឧបករណ៍ភ្លេង វត្ថុសិល្ប: ម៉ាស៊ីនដេរ កាំរទេះ ជាដើម។ ជាឈើមានតំលៃសេដ្ឋកិច្ចខ្ពស់ទាំងទីផ្សារក្នុងស្រុក ក៏ដូចជាសំរាប់នាំចេញ។ ក្រៅពីសាច់ឈើ ឫសរបស់វាក៏អាចប្រើប្រាស់ធ្វើជាគ្រឿងចម្លាក់ដោយដៃបានល្អដែរ។ បច្ចុប្បន្នប្រភេទនេះកំពុងស្ថិតក្នុងស្ថានភាពរងការគំរាមកំហែងយ៉ាងខ្លាំង ហើយអាចឈានទៅរកការបាត់បង់អស់ពីព្រៃធម្មជាតិបើយើងពុំមានវិធានការសង្គ្រោះអោយទាន់ពេលវេលាទេ។



គ្រឿងសង្ហារឹមធ្វើពីឈើក្រញូង

## ៤- លក្ខណៈរុក្ខសាស្ត្រ

**-ដើម:** ជាដើមឈើធំ មានស្លឹកពណ៌បៃតងជានិច្ច និង មានមែកសាខាច្រើន។ ដើមឈើមានកំពស់ ២៥-៣០ម និងមានអង្កត់ផ្ចិតជាមធ្យម ៦០ស.ម ជួនកាលអាចដល់ ១២០ស.ម។ សំបកពណ៌លឿងត្នោត-ព្រឿងៗ និងមានស្នាមប្រេះតូចៗតាមបណ្តោយនៃដើម ជួនកាលរបើកសំបកចេញដោយផ្ទែក។

**-ស្លឹក:** កន្សោមស្លឹកមានរាងដូចស្វៃរ។ ស្លឹកសមាសស្លាបសេសដុះឆ្លាស់គ្នាដែលមានប្រវែង ១៥-២០ស.ម។ កូនស្លឹកមានពី ៧-៩ ក្រាស់ដូចស្បែក ហើយស្លឹកដែលនៅខាងចុងមានទំហំធំជាងគេ។ កូនស្លឹកនីមួយៗមានរាងពងក្រពើមូលទ្រវែងដែលដុះឆ្លាស់គ្នា ឬ ដុះឈមបន្ទាប់គ្នា ដែលមានផ្នែកខាងចុងទាល់ ឬ មានចុងស្រួចហើយខ្លី។

**-ផ្កា:** ជាចង្កោម ឬ កួរ ដុះចេញពីក្លៀកនៃទងស្លឹក ផ្កាមានពណ៌ស។ ទំរត្របកផ្កាមាន ៥ ដែលផែកនៅខាងចុងកំពូលហើយគ្មានរោម។ ត្របកផ្កាត្រង់មានរាងដូចក្រញ៉ាំជើងសត្វ ជាធម្មតាមានរាងបួនជ្រុងទ្រវែង កេសរឈ្មោលមានចំនួន៩។

**-ផ្លែ:** ផ្លែវែងហើយរួមតូចខាងចុង សំបកផ្លែរាងសំប៉ែត មិនប្រេះ មានប្រវែងពី ៥-៦ស.ម ទទឹង ១ស.ម។ ក្នុងមួយផ្លែមានគ្រាប់ពី ១-៣ ហើយភាគច្រើនមានមួយគ្រាប់។

**-គ្រាប់:** គ្រាប់សំប៉ែតមានពណ៌ប្រផេះ ឬត្នោត ហើយមានទំហំ ៤មxម៧ម.ម។ ក្នុងមួយគីឡូក្រាមមានប្រហែល ៣៥ ០០០គ្រាប់។




## ៥- រដូវចេញផ្កា ផ្លែ

ប្រភេទឈើក្រញូងអាចចេញផ្កា ផ្លែចាប់ពីអាយុ ១៥-៣៥ឆ្នាំ គឺក្នុងកំឡុងពេលដែលធំពេញរូបរាង។ ក្នុងអាយុនេះដើមឈើមានទំហំអង្កត់ផ្ចិតចាប់ពី ២០-៣០ស.ម ។ នៅកម្ពុជាក្រញូងចេញផ្កាផ្លែក្នុងខែ ឧសភា-មិថុនា